**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ចាម**

លេខ.១៥១/១៧ ស.រ.ដល

កំពង់ចាម ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៨

រដ្ឋបាលខេត្តកំពង់ចាម មានកិត្តិយសសូមជម្រាបដល់អ្នកទទួលការ ទាំងអស់ឲ្យបានជ្រាបថា៖ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ សាលាខេត្តកំពង់ចាម នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៨ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៨។អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃនៅគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅក្នុងខេត្តកំពង់ចាម។

អ្នកទទួលការត្រូវបានបែងចែកជា ០៣ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារ និងការងារបេតុង ...។ល។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវគ្រួសក្រហម ...។ល។)
- ប្រភេទទី៣ ៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំហើយត្រូវមានបទពិសោធន៍ការអនុវត្តគម្រោង ទាក់ទងទៅនឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច ០២ក្នុងអំឡុងពេល ០៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ នឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើ លក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការ ជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងដាក់ជូនអភិបាល នៃគណៈអភិបាលខេត្តដើម្បីពិនិត្យ និងសម្រេច។ អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការសម្រាប់ឆ្នាំ២០១៨ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅ ទីចាត់ការផែនការ និងវិនិយោគ សាលាខេត្តកំពង់ចាម ចាប់ពីថ្ងៃទី ០២ ខែ តុលា រហូតដល់ថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០១៧ រៀងរាល់ម៉ោងធ្វើការ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមកក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគខេត្ត រួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅ ទីចាត់ការផែនការ និងវិនិយោគ សាលាខេត្តកំពង់ចាម ឬដោយទាញយកបានពីគេហទំព័ររបស់ គ ជ អ ប (www.ncdd.gov.kh) ដោយឥតបង់ថ្លៃ។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមអស់លោកអ្នកដែលមានបំណងដាក់ពាក្យចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការសម្រាប់ឆ្នាំ២០១៨ អញ្ជើញមកដាក់ពាក្យ តាមព័តមានដែលបានបិទផ្សាយនៅលើក្តារព័ត៌មាន ខាងមុខសាលាខេត្តកំពង់ចាម។

**អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម**

**គុច_ចំរើន**

<u>កន្លែងទទួល</u>

-ក្រសួងមហាផ្ទៃ

-លេខាធិការដ្ឋាន គ.ជ.អ.ប

-ក្រុមប្រឹក្សាខេត្ត

-ឯកសារកាលប្បវត្តិ